ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

# សេចក្តីប្រកាសព័ត៌មាន

## ឯកឧត្តមឯកអគ្គរាជទូតកម្ពុជា ជួបពិភាក្សាការងារជាមួយ អគ្គលេខាធិការ នៃមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន

ឯកឧត្តម ជុំ សុន្ទរី ឯកអគ្គរាជទូតតែងតាំង នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន បានជួបពិភាក្សាការងារជាមួយ លោកបណ្ឌិត ហ៊ីរ៉ាបាយ៉ាស៊ី គូនីហ៊ីកុ (**HIRABAYASHI Kunihiko**) អគ្គលេខាធិការ នៃមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន (AJC) នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ នៅទីក្រុងតូក្យូ។ កិច្ចប្រជុំនេះ បានធ្វើឡើងក្នុងបរិយាកាសស្និទ្ធស្នាល និងស្លាបនា ហើយបានរំលេចអំពីសារៈសំខាន់នៃ មជ្ឈមណ្ឌល AJC ជាស្ថានដ៏សំខាន់ក្នុងការជំរុញកិច្ចសហប្រតិបត្តិការអាស៊ាន-ជប៉ុន។

ក្នុងកិច្ចប្រជុំនេះ ឯកឧត្តមឯកអគ្គរាជទូតតែងតាំង បានសម្តែងការកោតសរសើរចំពោះភាពជាអ្នកដឹកនាំរបស់អគ្គលេខាធិការ និងការលះបង់លើការងាររបស់លេខាធិការដ្ឋាន AJC ហើយបានអបអរសាទរលោកបណ្ឌិត ហ៊ីរ៉ាបាយ៉ាស៊ី ចំពោះការតែងតាំងឡើងវិញរបស់លោកក្នុងអាណត្តិថ្មី។ ឯកឧត្តម បានស្វាគមន៍ចំពោះសមិទ្ធផលជាក់ស្តែងរបស់មជ្ឈមណ្ឌល រួមទាំងគំនិតផ្តួចផ្តើមដើម្បីបង្កើនភាពមើលឃើញយ៉ាងច្បាស់អំពីអាស៊ាននៅក្នុងប្រទេសជប៉ុន ជាពិសេសតាមរយៈសកម្មភាពដែលផ្សារភ្ជាប់ទៅនឹងពិព័រណ៍ពិភពលោក ២០២៥ អូសាកា កាន់សៃ។ ឯកឧត្តមឯកអគ្គរាជទូត បានបញ្ជាក់ជាថ្មីនូវការគាំទ្រយ៉ាងមុតមាំរបស់កម្ពុជាចំពោះមជ្ឈមណ្ឌល AJC និងអាណត្តិរបស់ខ្លួនចាប់តាំងពីកម្ពុជាបានក្លាយជាសមាជិកក្នុងឆ្នាំ២០០១ ជាពិសេសក្នុងការលើកកម្ពស់ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន។

ភាគីទាំងពីរ បានផ្លាស់ប្តូរទស្សនៈលើការពង្រឹងកិច្ចសហប្រតិបត្តិការនាពេលអនាគត រួមទាំងការគាំទ្ររបស់កម្ពុជាសម្រាប់ការរៀបចំ ផែនការយុទ្ធសាស្ត្រ AJC ឆ្នាំ២០២៦-២០៣០ ដើម្បីធានាថាផែនការនេះស្របទៅជាមួយអាទិភាពរយៈពេលវែងរបស់អាស៊ាន។ ឯកឧត្តមឯកអគ្គរាជទូត ក៏បានកោតសរសើរចំពោះការគាំទ្រជាបន្តបន្ទាប់របស់មជ្ឈមណ្ឌល AJC ចំពោះកម្ពុជា ជាពិសេសក្នុងការកសាងសមត្ថភាពទេសចរណ៍ និងគំនិតផ្តួចផ្តើមផ្តោតលើ CLMV និងបានគូសបញ្ជាក់ពីចំណាប់អារម្មណ៍របស់កម្ពុជាចំពោះកិច្ចសហប្រតិបត្តិការទាក់ទងនឹងការចាកចេញពី LDC។

នៅក្នុងបរិបទនេះ ឯកឧត្តមឯកអគ្គរាជទូត បានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការមជ្ឈមណ្ឌលអាស៊ាន-កម្ពុជា ដោយកត់សម្គាល់ពីការគាំទ្រដ៏មានតម្លៃរបស់មជ្ឈមណ្ឌលក្នុងការជំរុញវិស័យទេសចរណ៍កម្ពុជា ដោយពង្រឹងកម្មវិធីកសាងសមត្ថភាព និងការសម្របសម្រួលការផ្សព្វផ្សាយទៅកាន់ធុរកិច្ច

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh

ជប៉ុន និងដៃគូពាក់ព័ន្ធជប៉ុន។ ឯកឧត្តម បានបញ្ជាក់ពីការត្រៀមខ្លួនជាស្រេចរបស់កម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌល AJC បន្ថែមទៀត តាមរយៈសកម្មភាពរួមគ្នា ការចែករំលែកព័ត៌មាន និងការសម្របសម្រួលការផ្សព្វផ្សាយ ខណៈដែលស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងតូក្យូ បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយមជ្ឈមណ្ឌល AJC ដើម្បីជំរុញកិច្ចសហប្រតិបត្តិការជាក់ស្តែង ដែលផ្តល់នូវអត្ថប្រយោជន៍ជាក់ស្តែងសម្រាប់កម្ពុជា និងពង្រីកភាពជាដៃគូអាស៊ាន-ជប៉ុន កាន់តែទូលំទូលាយថែមទៀត៕

ថ្ងៃអង្គារ ២កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
តូក្យូ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦